FEED THE FUTURE
The U.S. Government's Global Hunger & Food Security Initiative


អ្នកនិពន្ធ៖

រ៉ូ សោភ័ណរិទ្ធ[1], ជា លាងស្រ៊ុន[1], នៅ ស្រីណៃត[1], ស រ័ត្ននា[1], ណោត លីដា[1],
ផេង ស៊ីណេត[1], ហៃម សុភារម្យ[1]

[1]មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ កម្ពុជា


ឈ្មោះគម្រោង៖

បង្កើនភាពធន់ទ្រាំនៃផលិតកម្មប៉េងប៉ោះទៅនឹងសីតុណ្ហភាពខ្ពស់នៃប្រទេសកម្ពុជា


ប្រភពថវិកា៖

ជំនួយពីពលរដ្ឋអាមេរិក USAID តាមរយៈមជ្ឈមណ្ឌលឧត្តមភាព ប្រពលវប្បកម្មកសិកម្មនិរន្តរភាព និងអាហារូបត្ថម្ភ



សម្រាប់ព័ត៌មានបន្ថែម៖

លោក ស រ័ត្ននា (៨៥៥) ០៨៧ ៥៩៩ ៨៧៥ | srathana@rua.edu.kh


កម្មវិធីផ្សព្វផ្សាយកសិកម្មស៊ីសេន

CE SAIN Agricultural Extension Program

កម្មវិធីនេះបំពេញមុខវេទិកាមួយដែលជួយសម្របសម្រួលដល់កសិករ ស្ថាប័នអប់រំ វិស័យឯកជន និងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការទទួលព័ត៌មាន ចំណេះដឹង បច្ចេកវិទ្យា និងនវានុវត្តន៍ទាក់ទងនឹងបច្ចេកទេសកសិកម្ម ដើម្បីធានាដល់ការផ្សព្វផ្សាយការអនុវត្តការគ្រប់គ្រងកសិកម្មល្អៗ។ កម្មវិធីនេះជួយធ្វើឲ្យប្រសើរឡើងនូវចំណេះដឹង និងការអនុវត្តបច្ចេកទេសកសិកម្មដោយផ្អែកលើនវានុវត្តន៍ និងការស្រាវជ្រាវវិទ្យាសាស្ត្រជាមូលដ្ឋាន។



# ការកាត់តមែកក្នុងផលិតកម្មដំណាំប៉េងប៉ោះ

បោះពុម្ពលើកទី១ ឆ្នាំ ២០២១

## Grafting in Tomato (*Lycopersicom eseulentum Mill.*) Production

First Edition 2021

អ៊ីម៉ែល៖ cesain@rua.edu.kh | គេហទំព័រ៖ www.cesain.org

USAID FROM THE AMERICAN PEOPLE

KANSAS STATE UNIVERSITY

# ការកាត់តមែកក្នុងផលិតកម្មដំណាំប៉េងប៉ោះ

ដើម្បីធ្វើការកាត់ អ្នកត្រូវរៀបចំ មែកត ជើងទម្រ រោងបន្ទំ និង សម្ភារៈមួយចំនួនសម្រាប់ធ្វើការកាត់ត។

## ជើងទម្រ

| ជើងទម្រប៉េងប៉ោះ | ជើងទម្រត្រប់ |
|---|---|
| សម្រាប់ដីមិនមានការលិចទឹក/ក្នុងផ្ទះសំណាញ់ | សម្រាប់ដីទីវាលមានលិចទឹក /ដីជាំទឹក |

⚠ ជើងទម្រប៉េងប៉ោះត្រូវតែជាជើងទម្រដែលមានការទទួលស្គាល់និងមានព័ត៌មានច្បាស់លាស់ថា វាជើងទម្រដែលត្រូវបានគេប្រើសម្រាប់ការកាត់តប៉េងប៉ោះ

## មែកត

រើសយកពូជប៉េងប៉ោះទិន្នផលខ្ពស់ និងមានលក្ខណៈតាមតម្រូវការរបស់ទីផ្សារទាំងទំហំ ពណ៌ និងគុណភាពផ្លែ

## ការរៀបចំរោងបន្ទំ

សីតុណ្ហភាព៖ ពី ២១C⁰-២៣C⁰ និងមិនលើសពី ៣០C⁰



ពន្លឺ៖ តិចតួចបំផុត

រោងបន្ទំត្រូវបានសាងសង់នៅក្រោមម្លប់ដើមឈើ/បរិវេណផ្ទះដែលមានម្លប់ ហើយការប្រើប្រាស់ប្លាស្ទិកសំណាញ់ពណ៌បៃតងនិងខ្មៅពីលើទៀត អាចជួយកាត់បន្ថយពន្លឺដែលជះទៅក្នុងរោងប្រហែល ៧០% ក៏ដូចជាជួយកាត់បន្ថយការឡើងកម្ដៅក្នុងរោងផងដែរ

សំណើម៖ ៧០%-៩០% ដោយប្រើប្លាស្ទិកប៉ូលីទីឡែនហុំព័ន្ធអាចជួយឲ្យរោងបន្ទំរក្សាសំណើម

## សម្ភារៈសម្រាប់ការកាត់




- កាំបិត / ឡាម
- ទឹកអាកុល ៧០ ដឺក្រេ
- ស្កុតរុំប៉ារ៉ាហ្វីម
- ឃ្នាប
- បំពង់ជ័រ

## ការកាត់ត

ជើងទម្រ: កាត់ដើមប្រវែង៥សមពីដីដោយពុះកណ្ដាលដើមប្រមាណ១សមទៅក្រោម

មែកត: វាស់មែកពីត្រួយខាងលើជិតដល់ស្លឹកដើមកំណើត។ បន្ទាប់ច្រៀកចុងដើមសងខាងដើម្បីយកទៅដោតលើជើងទម្រ។
* *គួរកាត់ស្លឹកចោលខ្លះ/ទុកតែត្រួយក៏ល្អដើម្បីកុំឲ្យបាត់បង់សារធាតុចិញ្ចឹមច្រើនពេក

ចុងក្រោយ យកស្កុតប៉ារ៉ាហ្វីមមករុំលើកន្លែងដែលបានកាត់តឲ្យជិតដោយធានាថាមិនឲ្យមានខ្យល់ចូលបាន

⚠ • ដំណើរការកាត់តតម្រូវឲ្យស្អាត និងមានអនាម័យទាំងអ្នកធ្វើការ ឧបករណ៍ប្រើប្រាស់ និងទីកន្លែងដោយប្រើប្រាស់អាកុលដើម្បីលាងសំអាត
- ដើម្បីដំណើរការការកាត់ត ជើងទម្រគួរតែមានអង្កត់ផ្ចិតដើមជាមធ្យមពី ១.៦-១.៨មម និងមែកត គួរតែមានដុះស្លឹកថ្មីពី ២-៣ស្លឹកសិន
- ការកាត់តនេះតម្រូវឲ្យជើងទម្រ និងមែតតមានទំហំប្រហាក់ប្រហែលគ្នាដើម្បីងាយស្រួលក្នុងការត តែមិនគួរឲ្យជើងទម្រមានអង្កត់ផ្ចិតតូចជាងមែកតទេ
- ត្រូវប្រាកដថា Cambium របស់ជើងទម្រ និងមែកត បន្សុីគ្នាល្អដើម្បីឲ្យដើមងាយសះជាប់គ្នា

## ការថែទាំ




ត្រូវយកកូនដែលបានកាត់តរួច ទៅដាក់ក្នុងរោងបន្ទំភ្លាមៗដោយមិនត្រូវដាក់កូននោះផ្ទាល់នឹងដីទេ (អាចយកដុំឥដ្ឋមកកល់)

ត្រូវគ្របសំណាញ់ពណ៌ខ្មៅ និងបៃតងក្នុងរោងបន្ទំដើម្បីរក្សាម្លប់រយៈពេល ២ ថ្ងៃ

⚠ រោងបន្ទំត្រូវបានរក្សាសំណើមពី ៧០-៩០% និង សីតុណ្ហភាពពី ២៥-៣២C។ ឧបករណ៍តាមដានសំណើម និងសីតុណ្ហភាពត្រូវបានប្រើប្រាស់ដើម្បីត្រួតពិនិត្យសីតុណ្ហភាពក្នុងរោងបន្ទំជាប្រចាំ។ នៅពេលសីតុណ្ហភាពក្នុងរោងឡើងកំដៅក្តៅ និងមានសភាពហប់ ការបើករោងឲ្យមានខ្យល់ចេញចូលញឹកញាប់ជារឿងដែលសំខាន់ ចំណែកក្នុងករណីសំណើមក្នុងរោងថយចុះ ការប្រើប្រាស់ឧបករណ៍បន្ថែមសំណើមជាការចាំបាច់។

ថ្ងៃទី៣ ក្នុងរោងបន្ទំ កូនដែលកាត់តនោះចាប់ផ្ដើមឡើងស្រស់វិញបណ្ដើរៗ ត្រូវកាត់បន្ថយម្លប់មកត្រឹម ៥០%ដោយធ្វើការដកសំណាញ់ប្លាស្ទិកខ្មៅចេញមួយស្រទាប់ទុកតែសំណាញ់បៃតង និងប្លាសិកថ្លា

ថ្ងៃទី៥ ត្រូវដកសំណាញ់បៃតងចេញដោយទុកតែប្លាស្ទិកថ្លា

ថ្ងៃទី៦ ត្រូវបើករោងបន្ទំ១២ម៉ោងដើម្បីឲ្យកូនដំណាំបន្សុាំ និងសីតុណ្ហភាពខាងក្រៅ

គ្រប់៧ថ្ងៃកូនដែលដាក់បន្ទុំក្នុងរោងអាចមានសភាពរឹងមាំគ្រប់គ្រាន់ នឹងយកចេញមកក្រៅ ហើយទុករយៈពេល ២ ទៅ ៣ ថ្ងៃបន្ថែមទៀតដើម្បីបន្សុាំនឹងបរិស្ថានមុនយកទៅដាំ

## ការដាំ និងគ្រប់គ្រង

- រៀបចំដី និងលើករោងឲ្យបានល្អ
- កត្តាសំខាន់នៅពេលដាំមិនត្រូវដាំកប់មុខរបួសដែលកាត់តនោះទេត្រូវមានគម្លាតឲ្យឆ្ងាយពី ដីចៀសវាងការឆ្លងជំងឺ
- កាត់មែកបែកខ្នែងពីគល់ទម្រចេញ ដើម្បីចៀសវាងការដណ្ដើមស្រូបយកសារធាតុចិញ្ចឹម និងកាត់ឬសដែលដុះចេញពីមែកតចេញ ដើម្បីប្រាកដថាវាមិនឆ្លងជម្ងឺផ្សេងៗតាមឬសនោះ
- ចំពោះកូនប៉េងប៉ោះដែលតជាមួយជើងត្រប់ គឺត្រូវការស្រោចទឹកឲ្យបានច្រើនជាងការដាំប៉េងប៉ោះធម្មតា ក្នុងករណីមិនមានធ្លាក់ភ្លៀងគ្រប់គ្រាន់ និងលក្ខខណ្ឌដីមានភាពស្ងួតខ្លាំង ព្រោះជើងត្រប់ត្រូវការទឹកច្រើន
- ការគ្រប់គ្រងកត្តាចង្រៃពីសត្វល្អិតផ្សេងៗគឺត្រូវតែអនុវត្តឲ្យបានខ្ជាប់ខ្ជួន។

